COMMUNITY LEGAL SERVICES OF PHILADELPHIA
Est. 1966
CLS

# ទទួលប្រាក់សង្គ្រោះសេដ្ឋកិច្ច ដោយការធ្វើឯកសារពន្ធរបស់លោកអ្នក

## ទោះបីជាធម្មតាលោកអ្នកមិនធ្លាប់ធ្វើក៏ដោយ!

ដើម្បីជួយឲ្យលោកអ្នកឆ្លងផុតពីជំងឺរាតត្បាត COVID-19 សេវាកម្មប្រាក់ចំណូលខាងក្នុង (IRS) បានបញ្ចេញប្រាក់សង្គ្រោះសេដ្ឋកិច្ចចំនួនបីលើក ប៉ុន្តែមនុស្សជាច្រើនមិនបានទទួលប្រាក់ទាំងអស់ដែលពួកគេគួរទទួលបាននោះទេ។ **ប្រសិនបើលោកអ្នកបានធ្វើឯកសារ ពន្ធរបស់លោកអ្នកនៅឆ្នាំនេះហើយ វានឹងជួយឲ្យលោកអ្នកទទួលបានប្រាក់ទាំងអស់នោះ ដែលលោកអ្នក និង គ្រួសារលោកអ្នកត្រូវបានគេជំពាក់**

## នេះជាមូលហេតុដែលលោកអ្នកគួរធ្វើឯកសារពន្ធដើម្បីទទួលបានប្រាក់សង្គ្រោះសេដ្ឋកិច្ចឲ្យបានឆាប់តាមដែលអាចធ្វើបាន៖

**លោកអ្នកប្រហែលជាមិនបានទទួលប្រាក់ទាំងអស់នោះ ដែលលោកអ្នក និង គ្រួសារលោកអ្នកត្រូវបានគេជំពាក់នោះទេ។**
ប្រសិនបើលោកអ្នកមិនមានចំណូលពីការងារ ឬ លោកអ្នកទទួលបានប្រាក់ពី អត្ថប្រយោជន៍ពិការភាព លោកអ្នកអាចទទួលបានប្រាក់សង្គ្រោះសេដ្ឋកិច្ចបានពេញលេញដោយធ្វើឯកសារពន្ធរបស់លោកអ្នកនៅ ពេលនេះ។

**ប្រសិនបើលោកអ្នកមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបានប្រាក់សង្គ្រោះសេដ្ឋកិច្ចណាមួយពីមុនទេ លោកអ្នកអាចនឹងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ប្រាក់សង្គ្រោះសេដ្ឋកិច្ចមួយនៅពេលនេះ។**
ច្បាប់ ដែលថាតើអ្នកណាអាចទទួលបានប្រាក់សង្គ្រោះសេដ្ឋកិច្ចនោះតែងមានការផ្លាស់ប្តូរជានិច្ច។ សូមធ្វើឯកសារពន្ធដើម្បីដឹង ថាតើលោកអ្នកត្រូវបានគេជំពាក់ប្រាក់ដែរឬទេ និង ដើម្បីធ្វើឱ្យងាយស្រួលក្នុងការទទួលបានប្រាក់នៅពេលអនាគត។

**លោកអ្នកអាចមានសិទ្ធិគ្រប់គ្រាន់ដើម្បីទទួលបានប្រាក់មួយចំនួនទៀត។**
ប្រសិនបើលោកអ្នកមានកូនដែលរស់នៅជាមួយលោកអ្នកចាប់តាំងពីឆ្នាំ 2020 មក លោកអ្នកអាចទទួលបានប្រាក់មួយចំនួនទៀតនៅចុងឆ្នាំ 2021។ លោកអ្នកអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីនឹងទទួលបានប្រាក់នេះ ដោយការធ្វើឯកសារពន្ធឆ្នាំ 2020 របស់លោកអ្នក។

**ធ្វើឯកសារពន្ធនៅពេលនេះ! កាលបរិច្ឆេទផុតកំណត់គឺនៅថ្ងៃទី 17 ខែឧសភា ឆ្នាំ 2021។**

## ទទួលបានជំនួយដោយឥតគិតថ្លៃដើម្បីធ្វើការធ្វើឯកសារពន្ធរបស់លោកអ្នក៖

- ប្រសិនបើលោកអ្នករកចំណូលបានតិចជាង $72,000 ក្នុងមួយឆ្នាំ លោកអ្នកអាចធ្វើឯកសារពន្ធរបស់លោកអ្នកដោយឥតគិតថ្លៃបាន ដោយប្រើឧបករណ៍សម្រាប់ធ្វើឯកសារពន្ធរបស់ IRS តាមរយៈគេហទំព័រដែលមានអាសយដ្ឋាន៖ tinyurl.com/IRSfreefiling
- មានជំនួយធ្វើឯកសារពន្ធដោយឥតគិតថ្លៃ។ សូមប្រើតំណភ្ជាប់នេះដើម្បីស្វែងរកទីតាំងធ្វើឯកសារពន្ធឥតគិតថ្លៃដែលនៅក្បែរលោកអ្នកតាមគេហទំព័រដែលមានអាសយដ្ឋាន tinyurl/com/IRStaxprep
- ប្រសិនបើលោកអ្នកមានអាយុចាប់ពី 50 ឆ្នាំឡើងទៅ សូមប្រើឧបករណ៍ AARP នេះដើម្បីស្វែងរកជំនួយធ្វើឯកសារពន្ធឥតគិតថ្លៃដែលនៅក្បែរលោកអ្នកតាមរយៈគេហទំព័រដែលមានអាសយដ្ឋាន tinyurl/com/AARP-free-tax-tool
- អ្នករស់នៅក្នុងតំបន់ Philadelphia អាចទទួលបានជំនួយដោយឥតគិតថ្លៃនៅ យុទ្ធនាការសម្រាប់គ្រួសារធ្វើការ។ កំណត់ពេលណាត់ជួប ឬ ធ្វើឯកសារពន្ធអនឡាញតាមគេហទំព័រដែលមានអាសយដ្ឋាន cwfphilly.org/resources/ ឬ ហៅទូរស័ព្ទទៅកាន់លេខ 215-454-6483 ។